**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**រដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ**
លេខ: ២៩៤ រទភ.ល

ថ្ងៃ ពុធ ៧កើត ខែ មិគសិរ ឆ្នាំខាល ចត្វាស័ក ព.ស.២៥៦៦
រាជធានីភ្នំពេញ ថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ២០២២

**ជម្រាបមក**
**លោកស្រីប្រធានក្រុមហ៊ុន អេ.ស៊ី.អ៊ី.អេស អ៊ិនជាសស្ទ្រៀស ឯ.ក**

**កម្មវត្ថុ** : ការសម្រេចជ្រើសរើស និងប្រគល់កិច្ចសន្យាស្តីពីការផ្គត់ផ្គង់គ្រឿងបន្លាស់ប្រព័ន្ធអគ្គិសនី។

**យោង** : កំណត់ហេតុបើកឯកសារដេញថ្លៃ ចុះថ្ងៃទី០២ ខែវិច្ឆិកា ឆ្នាំ២០២២ និងកំណត់ហេតុវាយតម្លៃប្រគល់កិច្ចសន្យា ចុះថ្ងៃទី២៤ ខែវិច្ឆិកា ឆ្នាំ២០២២ របស់គណៈកម្មាធិការលទ្ធកម្មរដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ។

សេចក្តីដូចមានចែងក្នុងកម្មវត្ថុ និងយោងខាងលើ សូមលោកស្រីប្រធានក្រុមហ៊ុនជ្រាបថាៈ ដោយផ្អែកលើកំណត់ហេតុវាយតម្លៃរបស់គណៈកម្មាធិការលទ្ធកម្ម រដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញសម្រេចជ្រើសរើស និងប្រគល់កិច្ចសន្យាជូន **ក្រុមហ៊ុន អេ.ស៊ី.អ៊ី.អេស អ៊ិនជាសស្ទ្រៀស ឯ.ក** ដើម្បីធ្វើការផ្គត់ផ្គង់គ្រឿងបន្លាស់ប្រព័ន្ធអគ្គិសនី ជូនរដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ ក្នុងតម្លៃទឹកប្រាក់សរុបចំនួន **២,១៦១,៦០៦,០៣៧.២៣ រៀល (ពីរប៊ីលានមួយរយហុកសិបមួយលានប្រាំមួយរយប្រាំមួយពាន់សាមសិបប្រាំពីររៀល និងម្ភៃបីសេន)** ជាតម្លៃកិច្ចសន្យា។

សូម លោកស្រីប្រធានក្រុមហ៊ុន ទទួលយកនូវការរាប់អានដ៏ស្មោះពីខ្ញុំ។

**អគ្គនាយក**

**ឡុង ណារ៉ូ**

ចម្លងជូន៖
-ក្រុមហ៊ុន មេត្រូឡូជី អ៊ិនស្រ្ទុមិន ថេសធីង សឺធីហ្វីខេសិន ឯ.ក
-ក្រុមហ៊ុន អេស.អិម.អូ.អិន ត្រេឌីង ឯ.ក

អគារ៤៥ ផ្លូវ១០៦ សង្កាត់ស្រះចក ខណ្ឌដូនពេញ ភ្នំពេញ ទូរស័ព្ទ: (៨៥៥) ២៣ ៦៣៥ ៨០ ៨០ Email: admin@ppwsa.com.kh